ការឈប់សម្រាកសម្រាប់គ្រួសារនិងការព្យាបាលទទួលប្រាក់ឈ្នួល (មាននិយោជិតចំនួន 25 នាក់ឬច្រើនជាង)

សូមអានការជូនដំណឹងនេះដោយផ្ទិតផ្ទង់ វាមានព័ត៌មានសំខាន់អំពីសិទ្ធិ ទំនួលខុសត្រូវនិងសិទ្ធិទទួលនៅក្រោមច្បាប់ ការឈប់សម្រាកសម្រាប់គ្រួសារនិងការព្យាបាលទទួលប្រាក់ឈ្នួល (PFML) រដ្ឋម៉ាស្សាជូសេត្ស។ សូមរក្សាការជូនដំណឹងនេះសម្រាប់កំណត់ត្រារបស់អ្នក។

ច្បាប់ PFML រដ្ឋម៉ាស្សាជូសេត្សផ្តល់និយោជិតរដ្ឋម៉ាស្សាជូសេតស៍ ផ្តល់ឱ្យ បុគ្គលិករដ្ឋម៉ាស្សាជូសេតស៍ភាគច្រើននូវសិទ្ធិទទួលបានប្រាក់ឈ្នួលគ្រួសារ និងការឈប់សម្រាកព្យាបាល។ សិទ្ធិទាំងនេះត្រូវបានពណ៌នាបន្ថែមទៀត នៅខាងក្រោមហើយរួមទាំង (1) ការការពារការងារនៅពេលដែលនិយោជិតត្រឡប់ទៅធ្វើការវិញនិង (2) អត្ថប្រយោជន៍ជំនួសប្រាក់ឈ្នួលមួយផ្នែក ខណៈពេលដែលនិយោជិតឈប់ធ្វើការ។ និយោជកអាចផ្តល់អត្ថប្រយោជន៍ទាំងនេះដោយ (1) ការចូលរួមក្នុងមូលនិធិ ទំនុកចិត្ត PFML ដែលដំណើរការដោយនាយកដ្ឋានការឈប់សម្រាប់គ្រួសារនិងព្យាបាលរដ្ឋម៉ាស្សាជូសេតស៍ (នាយកដ្ឋាន) ឬ (2) ការផ្តល់គម្រោងឯកជនលើកលែងដែលផ្តល់អត្ថប្រយោជន៍ យ៉ាងហោចជាសប្បុរសដូចអ្វីដែលមានតាមរយៈនាយកដ្ឋាន។

មិនថាបើនិយោជករបស់អ្នកចូលរួមក្នុងមូលនិធិទំនុកចិត្តរដ្ឋ ឬមានផែនការ ឯកជនក្តី អ្នកនឹងមានសិទ្ធិដើម្បីទទួលអត្ថប្រយោជន៍និងការការពារមួយចំនួន។ អ្នកអាចត្រូវបានតម្រូវឱ្យធ្វើការបរិច្ចាកទៅមូលនិធិទំនុកចិត្តឬដើម្បីផ្តល់មូលនិធិដល់គម្រោងឯកជនរបស់និយោជករបស់អ្នក ប៉ុន្តែបានត្រឹមតែចំនួនជាក់លាក់ប៉ុណ្ណោះ។ អ្នកក៏នឹងគួរតែប្រាប់និយោជករបស់អ្នកនៅពេលអ្នកឈប់សម្រាក ហើយអ្នកនឹងគួរតែ ដាក់ពាក្យសុំ សម្រាប់អត្ថប្រយោជន៍ជាមួយនាយកដ្ឋាន ឬតាមរយៈផែនការឯកជនរបស់និយោជក។

និយោជកអាចដាក់ពាក្យសម្រាប់ការលើកលែង ពីការបរិច្ចាកឈប់សម្រាក ព្យាបាល ការបរិច្ចាកសម្រាប់គ្រួសារឬទាំងពីរ។ និយោជករបស់អ្នកត្រូវតែផ្តល់ព័ត៌មានដល់អ្នកអំពីគម្រោងឯកជន និងដំណើរការដាក់ពាក្យ។ និយោជករបស់អ្នក បានធ្វើឱ្យមានព័ត៌មាន៖

- ☒ ក្នុងប្រអប់ខាងក្រោម
- ☐ ដូចជាសេចក្តីតភ្ជាប់ទៅនឹងការជូនដំណឹងនេះ
- ☒ រោគសញ្ញាដទៃទៀត៖ https://hr.mit.edu/employee-leaves

Massachusetts Institute of Technology
(ឈ្មោះនិយោជក)

PAID FAMILY AND MEDICAL LEAVE ACT (PFMLA) PLAN
(ឈ្មោះគម្រោងឯកជន)

(617) 253 – 6151
(លេខទូរស័ព្ទគម្រោងឯកជន)

MIT Human Resources, NE49-5000
Cambridge MA 02139
(អាសយដ្ឋានគម្រោងឯកជន)

- ☐ មិនមានគម្រោងឯកជនដែលត្រូវបានអនុម័តហើយកំពុងផ្តល់អត្ថប្រយោជន៍ការឈប់សម្រាកទាំងអស់តាមរយៈនាយកដ្ឋាន។
- ☒ បានផ្តល់ការអនុវត្តគ្រោងឯកជន សម្រាប់អត្ថប្រយោជន៍ឈប់សម្រាកសម្រាប់ គ្រួសារនិងព្យាបាល;
- ☐ មានគម្រោងឯកជនដែលត្រូវបានអនុម័ត សម្រាប់អត្ថប្រយោជន៍ការឈប់សម្រាកជាលក្ខណៈគ្រួសារតែប៉ុណ្ណោះ ហើយកំពុងផ្តល់អត្ថប្រយោជន៍ការឈប់សម្រាកព្យាបាលតាមរយៈនាយកដ្ឋាន។

https://hr.mit.edu/employee-leaves

(រឺបសែគម្រោងឯកជន)

☐ មានគម្រោងឯកជនដែលត្រូវបានអនុម័ត សម្រាប់អត្ថប្រយោជន៍ការឈប់សម្រាកព្យាបាលតែប៉ុណ្ណោះ ហើយកំពុងផ្តល់អត្ថប្រយោជន៍ការឈប់សម្រាកលក្ខណៈគ្រួសារតាមរយៈនាយកដ្ឋាន។

☐ N/A (នយោជកបរិច្ចាកចំពោះមូលនិធិឯកជន)

I. សេចក្តីពន្យល់អំពីអត្ថប្រយោជន៍

ការបែងចែកចំនួនម៉ោងឈប់សម្រាក។ នៅក្រោមច្បាប់ PFML អ្នកអាចទទួលរហូតដល់ចំនួន៖

- 12 សប្តាហ៍នៃការឈប់សម្រាកសម្រាប់គ្រួសារ ដែលទទួលប្រាក់ឈ្នួលក្នុងឆ្នាំ អត្ថប្រយោជន៍ដែលទាក់ទងនឹងកំណើត ការសុំកូនចិញ្ចឹម ឬកន្លែងចិញ្ចឹមកូន ដើម្បីថែទាំសមាជិកគ្រួសារ ដែលមានស្ថានភាពសុខភាពធ្ងន់ធ្ងរ ឬដោយសារការចាកចេញមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលកើតចេញពីការពិត។ ថាសមាជិកគ្រួសារកំពុងបំពេញកាតព្វកិច្ចសកម្ម ឬត្រូវបានជូនដំណឹងអំពីការអំពាវនាវដែលជិតមកដល់ ដើម្បីបំពេញកាតព្វកិច្ចសកម្ម នៅក្នុងកងកម្លាំងប្រដាប់អាវុធ។
- ចំនួន 20 សប្តាហ៍ការឈប់សម្រាកព្យាបាល ដែលទទួលប្រាក់ឈ្នួលក្នុងឆ្នាំអត្ថប្រយោជន៍ ប្រសិនបើពួកគេមានស្ថានភាពសុខភាពធ្ងន់ធ្ងរ ដែលធ្វើឲ្យពួកគេពិការពីការងារ។
- 26 សប្តាហ៍នៃការឈប់សម្រាកសម្រាប់គ្រួសារទទួលប្រាក់ឈ្នួលក្នុងឆ្នាំអត្ថប្រយោជន៍ ដើម្បីថែទាំសមាជិកគ្រួសារដែលជាសមាជិកសេវា ដែលមានការធានារ៉ាប់រង ដែលកំពុងទទួលការព្យាបាលវេជ្ជសាស្ត្រ ឬបើមិនដូច្នេះទេការដោះស្រាយផលវិបាកនៃស្ថានភាពសុខភាពធ្ងន់ធ្ងរទាក់ទងនឹងសេវាយោធារបស់សមាជិកគ្រួសារ។
- សរុបចំនួន 26 សប្តាហ៍ជាសរុបនៃគ្រួសារដែលបានបង់ និងការឈប់សម្រាកព្យាបាលនៅក្នុងឆ្នាំអត្ថប្រយោជន៍តែមួយ។

"ឆ្នាំអត្ថប្រយោជន៍" គឺ 12 ខែមុនថ្ងៃអាទិត្យភ្លាមៗមុនពេលការឈប់សម្រាក របស់អ្នកចាប់ផ្តើម។

ការឈប់សម្រាកដទៃទៀត។ ការឈប់សម្រាកណាមួយដែលអ្នកទទួលយក – បង់ប្រាក់ ឬមិនបង់ប្រាក់ – សម្រាប់ហេតុផលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចគ្នា ដែលបានរាយបញ្ជីខាងលើនឹងរាប់បញ្ចូលទៅ ក្នុងចំនួននៃការឈប់សម្រាករបស់អ្នកសម្រាប់ឆ្នាំអត្ថប្រយោជន៍នោះ។

សិទ្ធិទទួល។ អ្នកនឹងមានសិទ្ធិទទួលបានអត្ថប្រយោជន៍ការឈប់សម្រាកនិងប្រាក់ឈ្នួលជំនួស ប្រសិនបើអ្នកជួបនឹងការធ្វើតេស្តរកប្រាក់ចំណូល។ អ្នកត្រូវតែបានរកចូល យ៉ាងហោចណាស់ចំនួន 30 ដងលើសពីចំនួនអត្ថប្រយោជន៍រំពឹងទុក ហើយ បានបំពេញតាមតម្រូវការប្រាក់ចំណូលអប្បបរមាដែលត្រូវបានបង្កើតឡើងជារៀងរាល់ឆ្នាំដោយនាយកដ្ឋានជំនួយគ្មានការងារធ្វើ (DUA) , ដែលជាចំនួន $6,300 សម្រាប់ឆ្នាំ 2024, ក្នុងអំឡុងត្រីមាសប្រតិទិន 4 ចុងក្រោយ។ (នេះគឺជាចំនួនដែលបានគណនានៅក្នុងផ្នែក "ការទូទាត់ជំនួសប្រាក់ឈ្នួល" ខាងក្រោម។)

ការទូទាត់ជំនួសប្រាក់ឈ្នួល។ នៅពេលអ្នកប្រើពេលឈប់សម្រាកសម្រាប់មូលហេតុណាមួយដែលបានពណ៌នានៅខាងលើអ្នកនឹងមានសិទ្ធិដាក់ពាក្យសុំជាមួយនាយកដ្ឋាន ឬចំពោះគម្រោង ឯកជននិយោជករបស់អ្នក សម្រាប់

ការទូទាត់ជំនួសប្រាក់ឈ្នួល។ អត្ថប្រយោជន៍ទាំងនេះនឹងជាសមាមាត្រនៃប្រាក់ចំណូលប្រចាំសប្តាហ៍ ជាមធ្យមរបស់អ្នក។ ចំនួនអត្ថប្រយោជន៍សក្តានុពលអតិបរិមារបស់អ្នកនឹងមានចំនួនដូចខាងក្រោម៖

- 80% នៃប្រាក់ចំណូលរហូតដល់ 50% នៃប្រាក់ឈ្នួលប្រចាំសប្តាហ៍ជាមធ្យមរបស់រដ្ឋ
- 50% នៃប្រាក់ចំណូលលើសពីប្រាក់ឈ្នួលប្រចាំសប្តាហ៍ជាមធ្យមរបស់រដ្ឋ
- នៅក្នុងព្រឹត្តិការណ៍មិនលើសពីចំនួនអតិបរមា។ សម្រាប់ឆ្នាំ 2024 ចំនួនអត្ថប្រយោជន៍អតិបរមានេះគឺ $1149.90។ ចំនួននេះនឹងត្រូវបានកែតម្រូវជារៀងរាល់ឆ្នាំ ដោយផ្អែកលើការកើនឡើងនៃប្រាក់ឈ្នួលប្រចាំសប្តាហ៍ជាមធ្យមរបស់រដ្ឋ។

ផែនការឯកជនអាចជ្រើសរើសផ្តល់អត្ថប្រយោជន៍ខ្ពស់ជាង ប៉ុន្តែប្រហែលជាមិនផ្តល់ចំនួនទាបជាងអ្វីដែលនាយកដ្ឋាននឹងបង់នោះទេ។

<u>ការទូទាត់អត្ថប្រយោជន៍ស្រប។</u> ប្រសិនបើអ្នកទទួលអត្ថប្រយោជន៍ពីធនធានដទៃទៀត នៅពេលអ្នកកំពុងក៏ទទួលអត្ថប្រយោជន៍ពីនាយកដ្ឋាន អត្ថប្រយោជន៍ដែលអ្នកទទួលពីនាយកដ្ឋានអាចត្រូវបានកាត់បន្ថយ។ ប្រភេទមួយចំនួននៃអត្ថប្រយោជន៍ផ្សេងទៀតនឹងបណ្តាលឱ្យមានការកាត់បន្ថយអត្ថប្រយោជន៍មួយសម្រាប់មួយដែលអ្នកទទួលបានពីនាយកដ្ឋាន។ នេះមានន័យថាសម្រាប់ប្រាក់ដុល្លារនីមួយៗ ដែលអ្នកទទួលបានពីអត្ថប្រយោជន៍ទាំងនេះ អត្ថប្រយោជន៍របស់អ្នកពីនាយកដ្ឋាននឹងថយចុះមួយដុល្លារ។
អត្ថប្រយោជន៍ដែលនឹងមានឥទ្ធិពលនេះរួមមាន៖

- សំណងរបស់កម្មករ
- ការធានារ៉ាប់រងការមិនមានការធានារ៉ាប់រង
- គោលនយោបាយឬ កម្មវិធីពិការភាពអចិន្ត្រៃយ៍
- ការឈប់សម្រាកពីជំងឺបន្ថែមលើធនាគារឈប់សម្រាក

ទម្រង់នៃអត្ថប្រយោជន៍ផ្សេងទៀតនឹងមិនកាត់បន្ថយអត្ថប្រយោជន៍ ដែលអ្នកទទួលបានពីនាយកដ្ឋានទេ លុះត្រាតែអ្នកទទួលបានច្រើនជាងប្រាក់ឈ្នួលប្រចាំសប្តាហ៍ជាមធ្យមរបស់អ្នកនៅក្នុងអត្ថប្រយោជន៍សរុប។
អត្ថប្រយោជន៍ដែលនឹងមានឥទ្ធិពលនេះរួមមាន៖

- គោលនយោបាយ ឬកម្មវិធីពិការភាពបណ្តោះអាសន្ន (រួមទាំងពិការភាពរយៈពេលខ្លី និងពិការភាពរយៈពេលវែង)
- និយោជកគ្រប់គ្រងដោយគ្រួសារ និង/ឬគោលនយោបាយ ឬកម្មវិធីការឈប់សម្រាកព្យាបាល

<u>ដាក់បំពេញបញ្ចប់ការទូទាត់អត្ថប្រយោជន៍ PFML ។</u> សម្រាប់ពាក្យសុំដែលបានដាក់នៅ ឬក្រោយថ្ងៃទី 1 ខែវិច្ឆិកា ឆ្នាំ 2023 និយោជិតដែលទទួលបានអត្ថប្រយោជន៍ PFML អាចបំពេញបន្ថែម (ឬ "បិទ") អត្ថប្រយោជន៍ PFML របស់ពួកគេជាមួយនឹងការឈប់សម្រាកដែលមានប្រាក់បៀវត្សរ៍ដែលមាន (ពេលឈឺ វិស្សមកាល PTO ពេលវេលាផ្តាល់ខ្លួន។ល។)។ សម្រាប់និយោជិតដែលជ្រើសរើសបន្ថែមអត្ថប្រយោជន៍ PFML របស់ពួកគេតាមរបៀបនេះ ផលបូកនៃអត្ថប្រយោជន៍ PFML ប្រចាំសប្តាហ៍ និងអត្ថប្រយោជន៍ការឈប់សម្រាកដែលផ្តល់ដោយនិយោជកមិនអាចលើសពីប្រាក់ឈ្នួលប្រចាំសប្តាហ៍ជាមធ្យមរបស់និយោជិត (IAWW) បានទេ។ និយោជកនឹងទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និងធានាថាផលបូកប្រចាំសប្តាហ៍នៃអត្ថប្រយោជន៍ការឈប់សម្រាកដែលបានផ្តល់ដោយនិយោជក និងអត្ថប្រយោជន៍ PFML មិនលើសពី IAWW របស់និយោជិតនោះទេ។ និយោជកក៏ទទួលខុសត្រូវចំពោះការគ្រប់គ្រងការទូទាត់ណាមួយ ដែលបានបើកឱ្យនិយោជិតដែលមានចំនួនលើសពីចំនួន IAWW របស់និយោជិត។ នាយកដ្ឋាននិងជាប់ពាក់ព័ន្ធនឹងដំណើរការការទូទាត់ម្តងទៀត សម្រាប់ការទូទាត់លើសចំនួនឡើយ។ ដំណើរការនេះគឺជាការទទួលខុសត្រូវរបស់និយោជក និងនិយោជិតតែប៉ុណ្ណោះ។

ប្រសិនបើពាក្យសុំត្រូវបានដាក់នៅ ឬក្រោយថ្ងៃទី 1 ខែវិច្ឆិកា ឆ្នាំ 2023 កម្មវិធី ដែលបានដាក់ត្រឡប់មកវិញសម្រាប់ការឈប់សម្រាក ដែលបានចាប់ផ្តើម មុនថ្ងៃទី 1 ខែវិច្ឆិកា ឆ្នាំ 2023 មានសិទ្ធិក្នុងការបំពេញបន្ថែម។

II. សិទ្ធិនិងកិច្ចការពាររបស់និយោជិត

<u>ការការពារការងារ។</u> ជាទូទៅ ប្រសិនបើអ្នកឈប់សម្រាកពីគ្រួសារ ឬការឈប់សម្រាកពេទ្យ នៅពេលអ្នកត្រឡប់ទៅធ្វើការវិញ និយោជករបស់អ្នកត្រូវតែស្តារអ្នកទៅកាន់មុខតំណែងមុនរបស់អ្នក ឬទៅកាន់មុខតំណែងសមមូលជាមួយនឹងហាន:ដូចគ្នា ប្រាក់ឈ្នួល អត្ថប្រយោជន៍ការងារ តណទានរយៈពេលនៃសេវាកម្ម និងអតីតភាពការងារ។ ចាប់ពីថ្ងៃដែលអ្នកចាប់ផ្តើមការចាកចេញរបស់អ្នក។ នេះមិនអាចអនុវត្តបានប្រសិនបើមុខតំណែងរបស់អ្នកត្រូវបានបំបាត់ចោល ដោយព្រោះតែមូលហេតុខាងសេដ្ឋកិច្ច មិនទាក់ទងនឹងការប្រើការឈប់សម្រាករបស់អ្នក។

<u>ការបន្តការធានារ៉ាប់រងសុខភាព</u> និយោជករបស់អ្នកត្រូវតែបន្តផ្តល់សម្រាប់ បរិច្ចាកទៅការងាររបស់អ្នក អត្ថប្រយោជន៍ធានារ៉ាប់រងសុខភាពដែលទាក់ទងនឹងការងាររបស់និយោជិត ប្រសិនបើមាន កម្រិត និងក្រោមលក្ខខណ្ឌនៃការធានារ៉ាប់រងនឹងត្រូវបានផ្តល់ជូន ប្រសិនបើនិយោជិតបានបន្តធ្វើការជាបន្តបន្ទាប់សម្រាប់រយៈពេលនៃការឈប់សម្រាកបែបនេះ។ និយោជករបស់អ្នកអាចតម្រូវឱ្យអ្នកបន្តទូទាត់ចំណែកនៃបញ្ហាភការធានារ៉ាប់រងសុខភាពរបស់អ្នក ស្របតាមនៅលើលក្ខខណ្ឌដូចគ្នាមុនពេលឈប់សម្រាករបស់អ្នក។

<u>គ្មានការសងសឹក។</u> វាគឺខុសច្បាប់សម្រាប់និយោជកដើម្បីនឹងរើសអើង ឬសកសឹកជំទាស់នឹងអ្នកចំពោះការប្រើប្រាស់សិទ្ធិដែលខ្លួនមានសិទ្ធិទទួលនៅក្រោមច្បាប់ឈប់សម្រាក សម្រាប់គ្រួសារនិងព្យាបាលទទួលប្រាក់ឈ្នួល។ និយោជិត ឬអតីតនិយោជិតដែលត្រូវបានសងសឹកចំពោះការអនុវត្តសិទ្ធិក្រោមច្បាប់ អាចមានលើសពីបីឆ្នាំបន្ទាប់ពីការរំលោភនេះកើតឡើង បង្កើត បណ្តឹងរដ្ឋប្បវេណីស៊ីវិលនៅក្នុងតុលាការជាន់ខ្ពស់។

III. ចំនួនការបរិច្ចាក

ដើម្បីជួយមូលនិធិការឈប់សម្រាកទទួលប្រាក់ឈ្នួល ដែលមាននៅក្រោមច្បាប់ PFML និយោជករបស់អ្នកអាចធ្វើការការបរិច្ចាក ដោយទទួលបានមូលនិធិមួយផ្នែកដោយការកាត់ចេញពីប្រាក់ឈ្នួលរបស់អ្នក ដែលនឹងត្រូវបញ្ជូនទៅមូលនិធិទំនុកចិត្តមូលនិធិទំនុកចិត្ត ឬចំពោះប្រតិបត្តិករនៃគម្រោងឯកជនរបស់និយោជកអ្នក។ និយោជកដែលបរិច្ចាកទៅមូលនិធិទំនុកចិត្ត នឹងតម្រូវឱ្យធ្វើការបរិច្ចាកខាងក្រោម៖

ការបរិច្ចាកឈប់សម្រាកសម្រាប់គ្រួសារ	ការបរិច្ចាកឈប់សម្រាកព្យាបាល	ចំនួនការបរិច្ចាកសរុប
0.18% នៃប្រាក់ចំណូល*	**0.70% នៃប្រាក់ចំណូល***	**0.88% នៃប្រាក់ចំណូល***

ដោយសារតែនិយោជករបស់អ្នកមានកម្មករដែលមានការរ៉ាប់រង 25 នាក់ ឬ ច្រើនជាងនេះ ចំនួនទឹកប្រាក់នៃការបរិច្ចាកសរុបគឺ 0.88% នៃប្រាក់ឈ្នួល។

នៅក្រោមច្បាប់ និយោជកត្រូវទទួលខុសត្រូវចំពោះអប្បរមានៃ 60% នៃការបរិច្ចាកនៃការឈប់សម្រាកព្យាបាល (.42% នៃប្រាក់ឈ្នួល) ប៉ុន្តែត្រូវបានអនុញ្ញាតឱ្យកាត់ចេញពីប្រាក់ឈ្នួលរបស់និយោជិតរហូតដល់ 40% នៃប្រាក់រួមចំណែកនៃការឈប់សម្រាកព្យាបាល (.28% នៃប្រាក់ឈ្នួល) និងរហូតដល់ 100% នៃគ្រួសារទុកការបរិច្ចាក (.18% នៃប្រាក់ឈ្នួល) សម្រាប់សរុប .46% នៃប្រាក់ឈ្នួល។ ថ្វីបើនិយោជករបស់អ្នកមានផែនការឯកជន ឬចូលរួមក្នុងមូលនិធិទំនុកចិត្ត និយោជករបស់អ្នកមិនអាចកាត់លើសពីចំនួនភាគរយទាំងនេះ ពីប្រាក់ឈ្នួល របស់អ្នក។

និយោជករបស់អ្នកបានជ្រើសយកការបែងចែកចំនួនការបរិច្ចាកដូចខាងក្រោម៖

ការឈប់សម្រាកពេញ	ចំនួនបរិច្ចាកតម្រូវសារុប៖ .70%*			
	Massachusetts Institute of Technology (ឈ្មោះនិយោជក)	នឹងបរិច្ចាក	100%	នៃការបរិច្ចាកឈប់សម្រាកព្យាបាល
		និងចំនួនសេសសល់	___%	និងត្រូវកាតចេញពីប្រាក់ចំណូលរបស់អ្នក

ការឈប់សម្រាកសម្រាប់	ចំនួនបរិច្ចាកតម្រូវសារុប៖ .18%*			
	Massachusetts Institute of Technology (ឈ្មោះនិយោជក)	នឹងបរិច្ចាក	100%	នៃការបរិច្ចាកឈប់សម្រាកសម្រាប់គ្រួសារ
		និងចំនួនសេសសល់	___%	និងត្រូវកាតចេញពីប្រាក់ចំណូលរបស់អ្នក

សូមចាប់ផ្តើមនៅទីនេះ ដើម្បីបង្ហាញថាអ្នកយល់ថាភាគរយនៃប្រាក់ឈ្នួលរបស់អ្នកដែលរកបានក្នុងរយៈពេលប្រាក់ខែនឹងត្រូវបានកាត់ចេញពីប្រាក់ឈ្នួលរបស់អ្នករាល់អំឡុងពេលបង់ប្រាក់៖ _____

* ចំនួនលេខផ្តល់រហូតដល់ឆ្នាំ 2024។ អត្រាទាំងនេះអាចត្រូវបានកែតម្រូវលើមូលដ្ឋានប្រចាំឆ្នាំ ដែលមានប្រសិទ្ធភាពចាប់ពីថ្ងៃទី 1 ខែមករា នៃឆ្នាំប្រតិទិននីមួយៗ។

IV. ការជូនដំណឹងដល់និយោជករបស់អ្នក

មុន អ្នកឈប់សម្រាក ឬដាក់ពាក្យសុំអត្ថប្រយោជន៍ អ្នកត្រូវតែជូនដំណឹងទៅនិយោជករបស់អ្នកថាអ្នកត្រូវឈប់សម្រាក។ អ្នកនឹងតម្រូវឲ្យផ្តល់ការជូនដំណឹងយ៉ាងហោចណាស់ 30 ថ្ងៃនៃតម្រូវការសម្រាប់ការឈប់សម្រាក។ ប្រសិនបើការជូនដំណឹងរយៈពេល 30 ថ្ងៃមិនអាចធ្វើទៅបានដោយសារកាលៈទេសៈហួសពីការគ្រប់គ្រងរបស់អ្នក អ្នកត្រូវតែផ្តល់ការជូនដំណឹងឱ្យបានឆាប់តាមដែលអាចអនុវត្តបាន និងក្នុងព្រឹត្តិការណ៍ណាមួយ មុនពេលអ្នកដាក់ពាក្យស្នើសុំអត្ថប្រយោជន៍ណាមួយ។

នៅពេលអ្នកជម្រាបប្រាប់និយោជករបស់អ្នក អំពីតម្រូវការសម្រាប់ការឈប់សម្រាក អ្នកត្រូវតែផ្តល់ព័ត៌មានខាងក្រោម៖

1. កាលបរិច្ឆេទចាប់ផ្តើមនៃការចាកចេញដែលរំពឹងទុក;
2. រយៈពេលនៃការឈប់សម្រាកដែលរំពឹងទុក;
3. កាលបរិច្ឆេទរំពឹងទុកនៃការត្រឡប់មកវិញពីការឈប់សម្រាក;
4. ថាតើអ្នកនឹងត្រូវការការឈប់សម្រាកមិនទៀងទាត់ (ការចាកចេញដែលធ្វើឡើងក្នុងប្លុកដាច់ដោយឡែកពីពីរ ឬច្រើន) ឬកាត់បន្ថយការឈប់សម្រាក (ការឈប់សម្រាកដែលពាក់ព័ន្ធនឹងកាលវិភាគកាត់បន្ថយតិចជាងម៉ោង ឬថ្ងៃក្នុងមួយសប្តាហ៍) និង;
5. ប្រសិនបើអ្នកត្រូវការកាលវិភាគឈប់សម្រាកបណ្តោះអាសន្ន ឬកាត់បន្ថយ ភាពញឹកញាប់នៃការឈប់សម្រាក និងរយៈពេលរំពឹងទុកនៃករណីនៃការឈប់សម្រាកនីមួយៗ។

បើព័ត៌មាននេះផ្លាស់ប្តូរ អ្នកត្រូវតែប្រាប់និយោជករបស់អ្នកឱ្យបានឆាប់តាមដែលអ្នកបានដឹងអំពីការផ្លាស់ប្តូរ។

V. ការដាក់ពាក្យសុំ

ដើម្បីដាក់ពាក្យសុំ សម្រាប់អត្ថប្រយោជន៍ PFML អ្នកនឹងត្រូវការព័ត៌មានខាងក្រោមអំពីនិយោជករបស់អ្នក៖

Massachusetts Institute of Technology
(ឈ្មោះនិយោជក)
77 Massachusetts Avenue, Bldg NE49-5000
(អាសយដ្ឋានផ្លូវនិយោជក)

Cambridge, MA 02139
(ទីក្រុង រដ្ឋ ស៊ីបកូដនិយោជក)
042103594
(លេខអែឌីនិយោជកសហព័ន្ធ) (FEIN)

ប្រសិនបើនិយោជករបស់អ្នករួមចំណែកដល់មូលនិធិទំនុកចិត្ត អ្នកត្រូវតែដាក់ពាក្យស្នើសុំអត្ថប្រយោជន៍ជាមួយនាយកដ្ឋាន។ អ្នក អាចដាក់ទម្រង់បែបបទនេះ ក្នុងវិធីមួយនៃវិធីពីរ៖

1. អ្នកអាចបង្កើតគណនីមួយដើម្បីដាក់ពាក្យតាមអ៊ីនធឺណិតតាមរយៈគេហទំព័រកម្មវិធីរបស់នាយកដ្ឋាននៅ paidleave.mass.gov/login/
2. អ្នកអាចទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងលេខ របស់នាយកដ្ឋាន (833) 344-7365ដើម្បីបំពេញទម្រង់បែបបទតាមទូរស័ព្ទ។

សេចក្តីណែនាំទម្រង់បែបបទ និងពាក្យមានជូននៅគេហទំព័ររបស់នាយកដ្ឋាននៅ www.mass.gov/info-details/get-ready-to-apply-for-paid-family-and-medical-leave-pfml-benefits។

VI. សម្រាប់ព័ត៌មានបន្ថែម

សម្រាប់ព័ត៌មានមានសេចក្តីលំអិត សូមប្រឹក្សាវិបសៃរបស់នាយកដ្ឋាន៖ www.mass.gov/DFML។ អ្នកអាចទាក់ទងនាយកដ្ឋានការឈប់សម្រាកសម្រាប់គ្រួសារ និងព្យាបាលនៅ៖

The Massachusetts Department of Family and Medical Leave
PO Box 838
Lawrence, MA 01842
ទាក់ទងមជ្ឈមណ្ឌល៖ (833) 344-7365

<u>ការទទួលដឹង</u>

ហត្ថលេខារបស់អ្នកខាងក្រោមទទួលដឹងថា ការទទួលព័ត៌មានខាងលើរបស់អ្នក ក្នុងចំនួន 30 ថ្ងៃពីកាលបរិច្ឆេទចាប់ផ្តើមការងាររបស់អ្នក។

_____ _____

ហត្ថលេខា **កាលបរិច្ឆេទ**

_____

ឈ្មោះ (សរសេរច្បិត)

ការទទួលដឹងដោយបានចុះហត្ថលេខារបស់អ្នកនឹងត្រូវបានរក្សាទុកដោយនិយោជករបស់អ្នក។ សូមរក្សាសំណៅច្បាប់មួយ សម្រាប់សេចក្តីយោងរបស់អ្នកផ្ទាល់។